ឈ្មោះបេក្ខជន៖.........................................

ស្ថិតនៅក្រុម៖..........................................

សូមអបអរសាទរ អ្នកត្រូវបានជ្រើសរើស និងអញ្ជើញឲ្យចូលរួមក្នុងវគ្គផ្ដាច់ព្រ័ត្រដើម្បីក្លាយជាបេក្ខជនបេក្ខនារីទទួលជ័យលាភីក្នុងវគ្គសិក្សាសហគ្រិនដោយមិនគិតថ្លៃ នៅថ្ងៃទី ១៤ ខែមិនា ឆ្នាំ២០១៥ ចាប់ពីម៉ោង ៧:៣០នាទី ដល់ម៉ោង ១២:០០នាទី ព្រឹក។

បេក្ខជនម្នាក់ៗ ត្រូវបំពេញនូវសកម្មភាពបីជាប់ៗគ្នា ជាមួយក្រុមខ្លួន ដូចបានបញ្ជាក់ខាងក្រោម។

របៀបវារៈ

| ពេលវេលា | សកម្មភាព |
|---|---|
| ៧:៣០ -៧:៥០ - | ចុះឈ្មោះបេក្ខជន និងបេក្ខនារី |
| ៧:៥០ - ៨:០០ | បទបង្ហាញពីគោលបំណងកម្មវិធី |
| ៨:០០ - ៨:៣០ | ក្រុមពិភាក្សាទាក់ទងអាជីវកម្ម (រយះពេល ៣០នាទី) |
| ៨:៣៥- ០៩:៥០ | បទបង្ហាញ (រយះពេល ៥នាទីក្នុងម្នាក់) |
| ១០:០០- ១០:១០ | សម្រាក |
| ១០:១០- ១២:០០ | បទសម្ភាស (រយះពេល ១០នាទីក្នុងម្នាក់) |

**សកម្មភាពទី១៖ការពិភាក្សាជាក្រុម**

ពេលវេលា៖ ៣០នាទី

**ប្រធានបទ ៖**

១. ចូរជ្រើសរើស ប្រភេទអាជីវកម្មមួយដែលអ្នកគិតថាទទួលបានភាពជោគជ័យ ហើយយកវាមកពិភាក្សាហេតុអ្វីអាជីវកម្មនោះទទួលបានភាពជោគជ័យ។

២. ចូរជ្រើសរើស ប្រភេទអាជីវកម្មមួយដែលអ្នកគិតថាមិនបានទទួលភាពជោគជ័យ ហើយយកវាមកពិភាក្សា ហេតុអ្វីអាជីវកម្មនោះមិនអាចទទួលបានភាពជោគជ័យ។

បេក្ខជន និងបេក្ខនារី ត្រូវបានយកប្រធានបទខាងលើមកពិភាក្សាជាក្រុម ទាក់ទងនឹងអាជីវកម្មមួយដែលទទួលបានភាពជោគជ័យ និងមិនបានទទួលភាពជោគជ័យ។

## សកម្មភាពទី២ ៖ ការធ្វើបទបង្ហាញផ្ទាល់មាត់

ពេលវេលា៖ ៥នាទី

បេក្ខជន និងបេក្ខនារី ត្រូវបានផ្តល់ឲ្យករណីសិក្សាទាក់ទងនឹងអាជីវកម្មចំនួនមួយ ដើម្បីត្រៀមរៀបចំទុកជាមុន។

**ករណីសិក្សា**

សូមបេក្ខជន និងបេក្ខនារី គិតទៅដល់ប្រភេទអាជីវកម្មដែលខ្លួនមានគម្រោងនឹងធ្វើនាពេលអនាគត (ដូចដែលបានបញ្ជាក់នៅក្នុងពាក្យសុំចូលរៀន)។ ឥឡូវនេះ ជាពេលវេលាដែលអ្នកត្រូវធ្វើបទបង្ហាញនូវគំនិតអាជីវកម្មរបស់អ្នកទៅកាន់អ្នកវិនិយោគដែលមានសក្តានុពលជាច្រើននាក់ដែលកំពុងរង់ចាំស្តាប់នូវការបកស្រាយរបស់អ្នក ថាហេតុអ្វីបានជាពួកគាត់ត្រូវជ្រើសរើសអ្នក ដើម្បីវិនិយោគលើអាជីវកម្មរបស់អ្នក។

អ្វីដែលអ្នកត្រូវធ្វើនៅពេលនេះ អ្នកត្រូវរៀបចំនូវគំនិតអាជីវកម្មរបស់អ្នកឲ្យបានល្អ ស្វែងរកភស្តុតាងដើម្បីគាំទ្រដល់គំនិតទាំងនោះ ក៏ដូចជាផ្តល់នូវហេតុផលសមរម្យដែលអ្នកគិតថាអាជីវកម្មរបស់អ្នកពិតជាផ្តល់ប្រាក់ចំណេញ និងជោគជ័យ ដូចច្នេះអ្នកអាចធ្វើការបញ្ចុះបញ្ចូលវិនិយោគិនទាំងនោះបាន។ អ្នកក៏អាចនាំយកជាមួយនូវរូបភាព ឬក្រដាស់ផ្ទាំងធំ ដើម្បីគាំទ្រការបង្ហាញរបស់អ្នកផងដែរ។

ខាងក្រោមនេះ គឺជាសំណួរខ្លះៗដែលជាឧទាហរណ៍អាចជួយដល់ការរៀបចំរបស់អ្នក។

១. តើអាជីវកម្មរបស់អ្នកមានលក្ខណៈដូចម្តេចដែរ?

២. តើអ្នកណាខ្លះ ជាអតិថិជនគោលដៅរបស់អ្នក?



២

៣. ហេតុអ្វីបានជាអ្នកសម្រេចចិត្តបើកអាជីវកម្មនេះ និងនៅក្នុងទីតាំងនេះ?

៤. តើអ្វីទៅដែលអ្នកត្រូវធ្វើ ដើម្បីធ្វើឲ្យអាជីវកម្មនេះប្រព្រឹត្តទៅដោយភាពជោគជ័យ?

៥.តើអ្នកគិតថា អាជីវកម្មនេះមានសក្តានុពលអាចឈរបានក្នុងទីផ្សារដែរឬទេ និងមានអាយុកាលបានយូរប៉ុណ្ណាដែរ? សូមបញ្ជាក់ពីមូលហេតុ។

៦.តើអ្នកគិតធ្វើដូចម្តេចខ្លះ ដើម្បីធ្វើឲ្យអាជីវកម្មនេះមានភាពខុសប្លែកពីដៃគូប្រកួតប្រជែង ឬខុសពីអាជីវកម្មដ៏ទៃៗទៀត?

៧.តើអាជីវកម្មរបស់អ្នកនឹងមានលក្ខណៈ ឬរូបរាងបែបណាក្រោយពីបានទទួលជោគជ័យ?

៨. សូមផ្តល់ព័ត៌មានផ្សេងៗទៀត ដែលអ្នកគិតថាមានសារៈសំខាន់ និងជួយដល់ការសម្រេចចិត្តរបស់វិនិយោគិន។

ដើម្បីជួយអ្នកឲ្យទទួលបានជោគជ័យនៅក្នុងបទបង្ហាញនេះ យើងសូមជូនជាគន្លឹះខ្លះៗទុកជាគំនិតដល់ការរៀបចំរបស់អ្នក។ អ្នកគួរតែអនុវត្តនូវចំណុចដូចខាងក្រោមឲ្យបានល្អទាំងមុន និងក្នុងពេលធ្វើបទបង្ហាញ៖

១. រៀបចំព័ត៌មាន និងរកកស្តុតាងឲ្យបានគ្រប់គ្រាន់

២.ត្រៀមខ្លួនឲ្យបានរួចរាល់ទុកជាមុន

៣.អនុវត្តបទបង្ហាញរបស់អ្នកជាមួយមិត្តភ័ក្រ ឬក្រុមគ្រួសារជាមុន

៤. ទាក់ទាញអារម្មណ៍របស់អ្នកចូលរួម (បេក្ខជនដាក់ពាក្យ) ដោយប្រើក្រសែភ្នែកសំឡឹងទៅកាន់អ្នកចូលរួមឲ្យបានគ្រប់ៗគ្នា

៥. គោរពចំនួនពេលវេលាធ្វើបទបង្ហាញ គឺ ៥នាទី

**សកម្មភាពទី៣ ៖ ការសំភាសន៍**

ពេលវេលា៖ ១០នាទី ក្នុងមួយម្នាក់

បេក្ខជន និងបេក្ខនារី នឹងត្រូវបាន Assessor ធ្វើការសំភាសន៍ម្នាក់ម្តងៗ។